# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៥៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២០/៩២៤ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ .-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន

២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អនុប្រធានប្រចាំការ

៣- ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន

៤- ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អនុប្រធាន

៥- ឯកឧត្តម **ឈិត សុខុន** រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អនុប្រធាន

៦- ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន

៧- ឯកឧត្តម **អ៊ីន ចីរជោតិ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៨- ឯកឧត្តម **លេង វី** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៩- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

១០-ឯកឧត្តម **ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន

១១-ឯកឧត្តម **ឆែម គាតរិទ្ធី** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជារដ្ឋលេខាធិការ
ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិក

១២-ឯកឧត្តម **តួង ស៊ីផាន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១៣-ឯកឧត្តម **ឈីវ យីស៊ាង** រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៤-ឯកឧត្តម **សេន សុវណ្ណា** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១៥-ឯកឧត្តម **ឈឹម សៅគី** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១៦-ឯកឧត្តម **រាជ រ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

១៧-លោកជំទាវ **ប៉ែន ឆដា** រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល សមាជិកា

១៨-ឯកឧត្តម **ប៉ូច ប៊ុណ្ណាក់** រដ្ឋលេខាធិការក្រសួងផែនការ សមាជិក

១៩- លោកជំទាវ **ទេព បូរ៉ាមីន** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិកា

២០-ឯកឧត្តម **ទិន ពន្លក** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

២១-លោកជំទាវ **សេង វណ្ណសាយ** រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម សមាជិកា

២២-ឯកឧត្តម **ភឹម គុណាវឌ្ឍន៍** រដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

២៣-ឯកឧត្តម **ព្រហ្ម សិទ្ធត្រា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

២៤-លោកជំទាវ **វង់ មយុរា** រដ្ឋលេខាធិការក្រសួងទំនាក់ទំនង
ជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិកា

២៥-ឯកឧត្តម **សុខ ពុទ្ធិវុធ** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

២៦-ឯកឧត្តម **ឆា គ្រុយ** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

២៧-ឯកឧត្តម **ស៊ុយ សាន** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

២៨-ឯកឧត្តម **សោម សុគន្ធ** រដ្ឋលេខាធិការប្រចាំការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

២៩-លោកជំទាវ **អ៊ឹម ស៊ីថៃ** រដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិកា

៣០-ឯកឧត្តម **ហង្ស ឆាំឆាន** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ សមាជិក

៣១-ឯកឧត្តម **ឌី សមស៊ីដេត** អគ្គលេខាធិការនៃ **គ.ជ.ស.ជ.** សមាជិក។

**មាត្រា២ .-**

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត ត្រូវបំពេញភារកិច្ចដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨២០/៩២៤ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៣រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ